# សេចក្តីប្រកាសព័ត៌មានរួមរវាងក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# និង អង្គការសុខភាពពិភពលោក

ភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១០

## ការកើនឡើងនៃករណីរាកធ្ងន់ធ្ងរនៅក្នុងប្រទេសកម្ពុជា

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការណែនាំដល់សាធារណៈជនអំពីការកើនឡើងនូវចំនួនករណីរាកស្រួចស្រាវធ្ងន់ធ្ងរចាប់តាំងពីខែ វិច្ឆិកា ឆ្នាំ ២០០៩។ រហូតដល់បច្ចុប្បន្នមានករណីចំនួន ១២៨ ដែលបានបញ្ជាក់ថាមានជំងឺរាក "ដូចទឹកបាយ" ធ្ងន់ធ្ងរ បង្កដោយបាក់តេរីឈ្មោះ *Vibrio Cholerae* ដែលត្រូវបានរកឃើញនៅទីក្រុង ភ្នំពេញ ខេត្តកណ្តាល តាកែវ បន្ទាយមានជ័យ កំពង់ស្ពឺ និង ព្រៃវែង។ មានករណីចំនួន ១២៧ នាក់ត្រូវបានទទួលការព្យាបាលដោយជោគជ័យដោយការបង្គ្រប់ជាតិទឹក និង ថ្នាំផ្សះ ហើយបានជាសះស្បើយ។ មានបុរស អាយុ ៨២ ឆ្នាំ មកពីខេត្តតាកែវ បានស្លាប់ដោយសារផលវិបាកមកពីជំងឺនេះ នៅខែ មករា។

ក្រសួងសុខាភិបាល កំពុងបន្តតាមដានស្ថានការណ៍ តាមរយៈប្រព័ន្ធតាមដានថ្នាក់ជាតិ។ ក្រុមឆ្លើយតបបន្ទាន់ កំពុងធ្វើការអង្កេតនៅតាមកន្លែងដែលមានកើតជំងឺ ដើម្បីកំណត់រកប្រភពនៃជំងឺ និង ធ្វើការអប់រំដល់សហគមន៍ ក្នុងការបង្ការ និង គ្រប់គ្រងជំងឺ។ ឯកឧត្តម **ម៉ម ប៊ុនហេង** បានចុះសួរសុខទុក្ខគ្រួសារនៅក្នុងសហគមន៍ដែលមានកើតជំងឺ និងបានណែនាំអំពីរបៀបចៀសវាងការចំលងនៃជំងឺ។ ឯកឧត្តមបានមានប្រសាសន៏ថា: "*ការកើនឡើងនៃជំងឺរាកមិនមែនជារឿងមិនប្រក្រតីនោះទេក្នុងរយៈពេលនេះនៅប្រទេសកម្ពុជានៅពេលដែលទឹកមានកំរិតទាប ហើយប្រជាជនប្រហែលជាកំពុងប្រើប្រាស់ប្រភពទឹកមិនស្អាត*"។ "*ជំងឺអាចឆ្លង នៅពេលដែលប្រជាជនបរិភោគអាហារ ឬ ផឹក ទឹកដែលមានមេរោគ ដូច្នេះសូមថែរក្សាគ្រួសារអ្នកអោយមានសុវត្ថិភាព -លាងដៃអោយស្អាតមុនពេលចាប់កាន់អាហារ និង បន្ទាប់ពីបន្ទោរបង់ ដាំទឹកអោយពុះ ចំអិន និង គ្របអាហាររបស់ អ្នកអោយបានស្អាត*"។

ភាគច្រើននៃករណីនៃជំងឺរាកសុទ្ធតែទឹកអាចព្យាលបាលអោយបានជាសះស្បើយដោយការបង្គ្រប់ជាតិទឹក។ បានន័យថាអ្នកដែលមានជំងឺរាកសុទ្ធតែទឹកត្រូវផឹកទឹកភ្លាមៗអោយបានច្រើន និង ប្រើទឹកអូរ៉ាលីត (ORS)។ ទឹកអូរ៉ាលីតជាឱសថពិសេសសំខាន់សំរាប់ការពារ និង បំពេញមកវិញនូវកង្វះជាតិទឹកពីខ្លួនរបស់អ្នក ដែលបណ្តាលមកពីជំងឺរាកនេះ។ វាត្រូវបានផ្តល់ដោយឥត គិតថ្លៃនៅគ្រប់គ្រឹះស្ថានសុខាភិបាល និង អាចរកទិញបាននៅតាមហាង និង ឱសថស្ថាននានា។ អ្នកអាចប្រើទឹកអូរ៉ាលីត ដោយមិនចាំបាច់ធ្វើការពិគ្រោះជាមួយគ្រូពេទ្យ ឬ គិលានុប្បដ្ឋាក។ ចំពោះអ្នកដែលខ្វះជាតិទឹកធ្ងន់ធ្ងរ ឧទាហរណ៍ បើសិនជាគាត់ខ្សោយ

ខ្លាំងមិនអាចផឹកទឹកបាន ត្រូវតែបញ្ជូនជាបន្ទាន់ទៅកាន់មណ្ឌលសុខភាពដែលនៅជិតបំផុត ដើម្បីធ្វើការវាយតំលៃ និង ព្យាលបាលដោយបញ្ចូលសេរ៉ូមតាមសរសៃ។

ក្រសួងសុខាភិបាល បានធ្វើយុទ្ធនាការអនាម័យ លើការបង្ការ និង គ្រប់គ្រងជំងឺរាកតាមរយៈការចែកចាយនូវខិត្តប័ណ្ណអប់រំ បណ្តុះបណ្តាលឡើងវិញជូនបុគ្គលិកសុខាភិបាល គៀងគរសកម្មភាពនៅសហគមន៍ និង ការផ្សព្វផ្សាយតាមរយៈទូរទស្សន៍ជាតិ ដោយសហការណ៍ជាមួយដៃគូសុខភាពផ្សេងៗ។

ក្រសួងសុខាភិបាល និង បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃជំងឺនេះ តាមរយៈគេហទំព័ររបស់នាយកដ្ឋានប្រយុទ្ធ នឹងជំងឺឆ្លង www.cdcmoh.gov.kh ដែលនៅលើនោះអ្នកអាចទាញយកនូវសារអប់រំមួយចំនួនបាន។

សំរាប់ព័ត៌មានបន្ថែមទៀត ឬ សំរាប់រាយការណ៏ករណី ជំងឺរាកធ្ងន់ធ្ងរនៅក្នុងតំបន់របស់អ្នក សូមទាក់ទងមកលេខទូរស័ព្ទទាន់ហេតុការណ៏លេខ:

១១៥ ( មិនគិតថ្លៃ)

០១២ ៤៨៨ ៩៨១

០៨៩ ៦៦៩ ៥៦៧

សំរាប់ព័ត៌មានបន្ថែមទៀតសូមធ្វើការទាក់ទង:


**ក្រសួងសុខាភិបាល**

វេជ្ជបណ្ឌិត **សុខ ទូច**

ទូរសព្ទ័លេខ: +៨៥៥ ១២ ៨៥៦ ៨៤៨

វេជ្ជបណ្ឌិត **លី សូវ៉ាន់**

ទូរសព្ទ័លេខ: +៨៥៥ ១២ ៨២៥ ៤២៤

**អង្គការសុខភាពពិភពលោក**

វេជ្ជបណ្ឌិត **Pieter Van Maaren**

ទូរសព្ទ័លេខ: +៨៥៥ ២៣ ២១៦ ៦១០

វេជ្ជបណ្ឌិត **Nima Asgari**

ទូរសព្ទ័លេខ: +៨៥៥ ២៣ ២១៦ ៦១០